# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ០៥ ស.រ.៩៣

**សារាចរ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជំរាបមក**

ឯកឧត្តម ប្រធានតុលាការកំពូល

ឯកឧត្តម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

លោក ប្រធានសាលាឧទ្ធរណ៍

លោក អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

លោក ប្រធានតុលាការខេត្ត ក្រុង

លោក ព្រះរាជអាជ្ញាអមតុលាការក្រុង

លោក ប្រធានតុលាការយោធា

លោក ព្រះរាជអាជ្ញាអមតុលាការយោធា

សូមជ្រាប។

**កម្មវត្ថុៈ** ការណែនាំអនុវត្តច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ។

ច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ក្រសួងបានណែនាំផ្ទាល់អស់លោកចៅក្រម និងព្រះរាជអាជ្ញាក្នុងវគ្គបំពាក់ បំប៉នរួចហើយ។ ប៉ុន្តែក្រោយពីការណែនាំមក ក្រសួងបានសង្កេតឃើញថា អស់លោកចៅក្រម និងព្រះរាជអាជ្ញានៅ មានទស្សនៈផ្សេងៗពីគ្នា អំពីការងារបច្ចេកទេសដែលត្រូវវនូវត្តពាម ។ ដើម្បីជៀសវាងការមានទស្សនៈផ្សេងៗពីគ្នានេះ ក្រសួងមានករណីយកិច្ចណែនាំអំពីការងារបច្ចេកទេសសំខាន់ៗមួយចំនួនដូចតទៅ៖

### I. អំពីអយ្យការ

ជាគោលការណ៍ការងាររបស់ព្រះរាជអាជ្ញា ជធ្វើការចោទប្រកាន់ និងប្តឹងទៅសាលាជំនុំជំរះក្តីអំពីរាល់បទ ល្មើសព្រហ្មទណ្ឌ ដើម្បីការពារការប៉ះពាល់ដល់សន្តិសុខសាធារណៈ និងរបៀបរៀបរយសាធារណៈ។ ដូច្នេះពាលបើបាន ទទួលពាក្យបណ្តឹង ឬកំណត់ហេតុរបស់នគរបាលយុត្តិធម៌ ស្តីពីបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវពិនិត្យ និងចាត់វិបាន ការដូចតទៅៈ

១. បើពិនិត្យទៅឃើញថា មិនចូលជាបទព្រហ្មទដែលច្បាប់កំណត់អោយផ្តន្ទាទោសទេ ព្រះរាជអាជ្ញាសំរេចដំកល់រឿងទុកមិនចាត់ការតាមលិខិតសំរេច ហើយជូនដំណឹងដល់ដើមបណ្តឹងក្នុងរយៈពេលមិនអោយលើសពី ២ខែ យ៉ាងយូរចាប់តាំងពីថ្ងៃទទួលពាក្យបណ្តឹង ដើម្បីទុកឱកាសអោយដើមបណ្តឹងប្តឹងទៅសាលាឧទ្ធរណ៍អំពីសេចក្តីសំរេចនេះ ហើយត្រូវចុះនិទ្ទេសក្នុងសៀវភៅទទួលពាក្យបណ្តឹង និងលើកំណត់ហេតុ ឬបណ្តឹងនោះជាសំគាល់ផង ។

២. បើពិនិត្យទៅឃើញថា បទល្មើសនោះជាបទមជ្ឈឹម ឬក្រឹដ្ឋ ដែលច្បាប់តម្រូវអោយផ្តន្ទាទោសទោសទោះបីជាសំណុំរឿងមាន ឬដ្ឋាន នាំខ្លួនបុគ្គលប្រព្រឹត្តល្មើសព្រះរាជអាជ្ញាចាំបាច់ត្រូវចាត់អោយស៊ើបអង្កេតភ្លាម ដោយធ្វើដីកាសន្និដ្ឋានមួយហៅថា " ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ" ។ ដីកានេះព្រះរាជអាជ្ញាត្រូវផ្តើមចោទប្រកាន់ ចង្អុលអោយចំជនប្រព្រឹត្តបទល្មើស អំពីបទល្មើស និងបញ្ជាក់អំពីអត្ថបទច្បាប់ រួចហើយបញ្ជូនដីកា និងសំណុំរឿងនោះទៅចៅក្រម ដើម្បីអោយចៅក្រមស៊ើបអង្កេតតាមច្បាប់។

៣. ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរនេះ បើព្រះរាជអាជ្ញាយល់ថាជាការចាំបាច់ ព្រះរាជអាជ្ញា មានសិទ្ធិសន្និដ្ឋានសុំអោយចៅព្រមស៊ើបសួរ ឃុំខ្លួនជនប្រព្រឹត្តបទល្មើសបាន ប៉ុន្តែសេចក្តីសន្និដ្ឋានចុងក្រោយនេះ ពុំមែនជា បំណងបង្ខំអោយចៅក្រមស៊ើបសួរសំរេចតាមនេះទេ ប្រសិនបើចៅក្រមនេះយល់ឃើញផ្សេងពីនេះ ក្នុងករណីដែលចៅ ព្រមស៊ើបសួរយល់ឃើញផ្សេងពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជរោជ្ជា ចៅក្រមនេះមានកាតព្វកិច្ចបញ្ជូនដីតាសំរេចរបស់ខ្លួន ទៅលោកព្រះរាជអាជ្ញាភ្លាម មួយអន្លើដោយសំណុំរឿង ដើម្បីមានលទ្ធភាពចាត់ការតាមច្បាប់តទៅ។ ព្រះរាជអាជ្ញា មានសិទ្ធិប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ពង់កាសំរេចនោះភ្លាម ឬមិនធ្វើការប្តឹងជំទាស់ក៏បាន។

៤. បើពិនិត្យទៅឃើញថា មិនច្បាស់លាស់ចំពោះសំណុំរឿង ដែលគ្មាននាំខ្លួនបុគ្គល ហើយមិនអាចសន្និដ្ឋានបាននូវបទល្មើសអ្វីនោះ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចចាត់វិធានការស៊ើបអង្កេតជាបឋមដោយផ្ទាល់ដើម្បីរកភស្តុតាង ធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់។ បើមានភស្តុតាងអាចចោទប្រកាន់បាន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានតាមរបៀប ខាងលើបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតបើយល់ថា ការចាំបាច់ ឬមួយបើការអង្កេតផ្ទាល់នោះអាចប្រមូលភស្តុតាងបានគ្រប់គ្រាន់អាចនឹងដាក់ជូនតុលាការជំនុំជំរះបាន ព្រះរាជអាជ្ញាមិនចាំបាច់ជូនទៅចៅក្រមស៊ើបអង្កេតទេ <u>ដើម្បីធ្វើដីកាផ្តើម ចោទប្រកាន់បញ្ជូនរឿងទៅតុលាការជំនុំជំរះតែម្តង។</u> ក្នុងករណីដែលធ្វើបែបនេះបានលុះណាតែបទល្មើសនោះ ច្បាប់តម្រូវអោយផ្តន្ទាទោសដាក់គុកអតិបរិមានៃទោសមិនលើសពី ១ឆ្នាំ។

៥. បើត្រូវពិនិត្យលើកំណត់ហេតុរបស់អង្គភាពគយ រុក្ខាប្រម៉ាញ់ ជលផល ឬពន្ធដា ដែលអំពើល្មើសបំពានលើច្បាប់ធយ វុក្ខាប្រម៉ាញ់ ជលផល និងពន្ធដារ ព្រះរាជអាជ្ញាត្រូវផ្តើមចោទប្រកាន់បញ្ជូនរឿងទៅពុលាការជំនុំជំរះ ផ្ទាល់តែម្តង ដោយចាត់ទុកកំណត់ហេតុរបស់អង្គភាពនោះជាភស្តុតាងបន្ទុកសំរាប់ធ្វើការចោទប្រកាន់ និងឃាត់រឿងជូនទៅ តុលាការជំនុំជំរះ ។

៦. ចំពោះបទល្មើសឧក្រឹដ្ឋប្រព្រឹត្តដោយជាក់ស្តែង ព្រះរាជអាជ្ញាមានសិទ្ធិអំណាចធ្វើសកម្មភាពផ្ទាល់ជាមួយនគរបាលយុត្តិធម៌ចុះទៅពិនិត្យអង្កេតស្រាវជ្រាវដល់ទីកន្លែង ដោយសួរយកចម្លើយជនប្រព្រឹត្តបទល្មើស ឆែកឆេរ ឃាត់ទុក ឬរឹបអូសភ័ស្តុតាង និងងសួរយកចម្លើយសាក្សី។ ល។ ក្រោយពីបានទទួល

កំណត់ហេតុ ស្តីពីការដល់ខ្លួនបានចុះពិនិត្យដល់ទីកន្លែង ព្រះរាជអាជ្ញាត្រូវធ្វើដីការសន្និដ្ឋានតាមរបៀបគ្នាខាងលើ បញ្ជូនរឿងទៅចៅក្រម ដើម្បីអោយស៊ើបសួរតាមច្បាប់ ។

៧. អំពីបទល្មើសមជ្ឈឹមជាក់ស្តែងដែលច្បាប់តម្រូវអោយពន្ធនាគារមិនលើសពី ១ឆ្នាំ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចធ្វើអង្កេតផ្ទាល់ភ្លាមៗនៅពេលទទួលសំណុំរឿង និងខ្លួនជនល្មើស និងផ្តើមចោទប្រកាន់បញ្ជូនរឿង និងជនល្មើសទៅតុលាការជំនុំជំរះបានដោយមិនចាំបាច់ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងទៅចៅក្រមធ្វើអង្កេតបន្ថែមទៀតទេ។

៨. ក្នុងករណីដែលបទល្មើសជាឧក្រិដ្ឋ ឬមជ្ឈឹម ដែលព្រះរាជអាជ្ញាយល់ថាមានទម្ងន់ពិសេស ព្រះរាជអាជ្ញាត្រូវអោយដំណឹងភ្លាមៗ តាមរបៀបណាមួយដែលអាចធ្វើជាបន្ទាន់បានទៅវត្តព្រះរាជនាជ្ញាអមសាលាឧទ្ធរណ៍ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់ទាំងឡាយ ដែលខ្លួនបានទទួលពីមន្ត្រីទាំង ២ ខាងលើនេះ ជាដរាប។

៩. <u>ទំនាក់ទំនងការងាររវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត៖</u>

ព្រះរាជអាជ្ញាត្រូវតាមដាន និងត្រួតពិនិត្យរាល់សកម្មភាពរបស់ចៅក្រមស៊ើបអង្កេតតាមរយៈ "ដីកាបញ្ជូនរឿងអោយពិនិត្យ" របស់ចៅក្រមស៊ើបអង្កេតដែលបញ្ជូនមកអោយពិនិត្យ។ ក្នុងលក្ខណៈនោះគឺបែបនេះ ព្រះរាជអាជ្ញា ត្រូវត្រួតពិនិត្យមើលសំណុំរឿងនោះអោយបានច្បាស់លាស់ បើយល់ឃើញថាសំណុំរឿងនោះមានភស្តុតាងគ្រប់គ្រាន់អង្កេត បានមូលពិតមែនហើយអាចនឹងដាក់ជូនទៅតុលាការជំនុំជំរះបាន ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួននៅលើកាបញ្ជូនរឿងអោយពិនិត្យរបស់ចៅក្រមស៊ើបអង្កេតក៏បាន ឬធ្វើសេចក្តីដ្ឋានដោយឡែកក៏បាន ប្រយោជន៍អោយចៅក្រមស៊ើបអង្កេតធ្វើដីកាបញ្ជូនរឿងទៅតុលាការដើម្បីជំនុំជំរះ . ប្រសិនបើចៅក្រុមនេះយល់ឃើញដូចគ្នា។ ម្យ៉ាងទៀតបើព្រះរាជអាជ្ញាពិនិត្យទៅ ឃើញថា សំណុំរឿងទោះគ្មានភស្តុតាងគ្រប់គ្រាន់មិនអាចដាក់ជូនតុលាការជំនុំជំរះបានទេនោះ ព្រះរាជាអាជ្ញាត្រូវធ្វើ សេចក្តីសន្និដ្ឋានរបស់ខ្លួននៅលើដីកាបញ្ជូនរឿងអោយពិនិត្យរបស់ចៅពក្រមស៊ើបអង្កេតក៏បាន ដើម្បីអោយចៅក្រមស៊ើបអង្កេតធ្វើដីការលើកលែងចោទប្រកាន់ ប្រសិនបើចៅក្រមស៊ើបអង្កេតយល់ឃើញដូចនេះដែរ។

ប្រសិនបើព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ យល់ឃើញមិនដូចគ្នា លើសំណុំរឿងតែមួយ។ ឧទាហរណ៍ ព្រះរាជអាជ្ញាយល់ថាមានពិរុទ្ធលើជនដែលបានចោទប្រកាន់ ឯចៅក្រមស៊ើបសួរយល់ថាគ្មានពិរុទ្ធដោយផ្អែកលើមូលហេតុដូចជារឿងមានលក្ខណៈរដ្ឋប្បវេណីជាដើម ហើយចៅពក្រមស៊ើបសួរនោះសំដៅលើកលែងចោទប្រកាន់តាមដីការសំរេចនោះ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចបញ្ជូនសំណុំរឿង និងការសំរេចភ្លាមៗ ដើម្បីព្រះរាជអាជ្ញាមានលទ្ធភាពប្តឹងជំទាស់ក្នុងកំណត់ច្បាប់។

ម្យ៉ាងទៀតបើចៅក្រមស៊ើបអង្កេតបានស្នើសុំអោយព្រះរាជអាជ្ញាផ្តើមចោទប្រកាន់បទល្មើសផ្សេងក្រៅអំពីបទល្មើសដែលខ្លួនបានចោទប្រកាន់នោះព្រះរាជអាជ្ញាត្រូវតែផ្តើមចោទប្រកាន់បន្ថែមទៀត ដើម្បីអោយចៅក្រមស៊ើបអង្កេត មានសិទ្ធិស្រាវជ្រាវស៊ើបអង្កេតលើបទល្មើសដែលលេចឡើងនោះ ។

១០. ក្រៅពីករណីកិច្ចខាងលើ ព្រះរាជអាជ្ញាត្រូវមានកាតព្វកិច្ចចូលរួមក្នុងសវនាការជំនុំជំរះ ដោយខាន ពុំបានតាមការកំណត់របស់ច្បាប់ ដើម្បីការពារបណ្តឹងចោទរបស់ខ្លួន និងការពារផលប្រយោជន៍ច្បាប់។ ក្នុងរឿងរដ្ឋប្បវេណី ព្រះរាជអាជ្ញាក៏មានអំណាចចូលរួមសវនាការនោះដែរ បើយល់ឃើញថាជាការចាំបាច់។

ប៉ុន្តែចំពោះរឿងណាដែលប៉ះពាល់ ដល់របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់ផលប្រយោជន៍អសមត្ថជន ព្រះរាជអាជ្ញាចាំបាច់ត្រូវតាំងខ្លួនជាគូក្តីដើម ហើយចូលរួមក្នុងសវនាការដោយបានពុំបាន ដូចនេះព្រះរាជអាជ្ញា មានសិទ្ធិប្តឹងជំទាស់គ្រប់សេចក្តីសំរេចរបស់ចៅព្រមស៊ើបសួរ បើយល់ថាជាការចាំបាច់នឹងប្តឹងឧទ្ធរណ៍ក្នុង រឿងព្រហ្មទណ្ឌទាំងអស់ បើយល់ឃើញថាការសំរេចរបស់តុលាតមិនត្រឹមត្រូវ តាមច្បាប់ដោយហេតុតុលាការ បានសំរេចអោយជនល្មើសរួចខ្លួន ឬដាកគុកជនល្មើសកំរិតធ្ងន់ធ្ងរពេក ឬដាកគុកជនល្មើសកំរិតទាបពេក។ ចំណែករឿងរដ្ឋប្បវេណីវិញ បើរឿងណាដែលព្រះរាជអាជ្ញាបានតាំងខ្លួនជាពគូក្តីដើម ទើបមានសិទ្ធប្តឹង ឧទ្ធរណ៍បាន។

## II- ចៅក្រមស៊ើបអង្កត

ចៅក្រមស៊ើបអង្កេត មានសិទ្ធិអំណាចទទួលស៊ើបអង្កេតគ្រប់រឿងព្រហ្មទណ្ឌ ដែលអយ្យការបានធ្វើ កាសន្និដ្ឋានបញ្ជូនរឿងមកអោយខ្លួនស៊ើបអង្កេត ហើយដែលនៅក្នុងដីការនោះព្រះរាជអាជ្ញាបានចោទប្រកាន់ ជនល្មើស និងបង្ហាញមាត្រាច្បាប់តម្រូវអោយផ្តន្ទាទោស ដូច្នេះក្នុងករណីបែបនេះ ចៅក្រមស៊ើបអង្កេតមាន សិទ្ធិ និងកាតព្វកិច្ចដូចតទៅៈ

១. ការបើបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបអង្កត ត្រូវបង្កសំណុំរឿងហើយចុះក្នុង សៀវភៅស៊ើបសួរ រួចចាត់ការតាមលំដាប់លំដោយដូចដែលមានចែងក្នុងនីតិវិធី ដូចជាសួរចម្លើយជនជាប់ ចោទ នៅចំពោះមុខមេធាវី បើមានមេធាវី ជនរងគ្រោះ សាក្សី និងចាត់ការផ្សេងទៀត ដូចជាចាត់ឱ្យធ្វើ កោសល្យវិច័យ ឬចុះទៅពិនិត្យដល់មូលដ្ឋាន ដោយខ្លួនឯង ដើម្បីស្រាវជ្រាវប្រមូលភស្តុតាង វត្ថុធាតុផ្សំបទ ល្មើសតាមការចោទរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែ ក្នុងពេល កំពុងស៊ើបអង្កេតនេះ បើស្រាវជ្រាវទៅឃើញមាន លេចឡើង បទល្មើសព្រហ្មទណ្ឌផ្សេងក្រៅអំពីបទល្មើសដែលព្រះរាជអាជ្ញា បានចោទប្រកាន់ គប្បីចៅក្រម ស៊ើបអង្កេតធ្វើកាបញ្ជូនរឿងនោះត្រឡប់ទៅព្រះរាជអាជ្ញាវិញ ដើម្បីសុំអោយព្រះរាជអាជ្ញា ផ្តើមចោទប្រកាន់នូវ បទល្មើស ដែលទើបលេចថ្មីនេះ លើកលែងតែបទល្មើសខ្ចីនោះជាបទលហុ។ កាលបើបានទទួលការ ចោទ ប្រកាន់ថ្មី ទើបចៅក្រមស៊ើបសួរមានសិទ្ធិអំណាចធ្វើការរង្កេតលើរឿងហេតុលេចថ្មីនោះបាន ។ បើព្រះរាជ អាជ្ញាមិន បានផ្តើមចោទប្រកាន់ថែមទៀតទេ ខ្លួនគ្មានអំណាច និងធ្វើអង្កេតលើបទល្មើសនេះទេ។ នេះជា គោលការណ៏សំខាន់បញ្ជាក់ ក្នុងមាត្រា ៧០ និង ៧១ នៃច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

សរុបមកចៅក្រមស៊ើបអង្កេត ធ្វើអង្កេតតែតាមការចោទប្រកាន់របស់អយ្យការតែប៉ុណ្ណោះ ។

២. ក្នុងពេលកំពុងស៊ើបសួរ តាមការយល់ឃើញរបស់ខ្លួន ចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចសំរេច ឃុំខ្លួនជនល្មើសតាមដីការសំរេច ដើម្បីការពារជនល្មើសពុំឱ្យរត់រួចខ្លួនពីការទទួលទោស ឬកុំឱ្យជនល្មើស បំបាត់ភស្តុតាង ហើយ ក៏មានអំណាចសំរេចមិនឃុំខ្លួនជនល្មើសដែរ ដោយមានដាក់ប្រាក់បាន ឬគ្មានដាក់ ប្រាក់ធានា បើខ្លួនយល់ឃើញថា ជនល្មើសនេះ ប្រព្រឹត្តបទល្មើសជាបទមជ្ឈឹមកំរិតទាប ហើយជនល្មើសមាន ទីលំនៅច្បាស់លាស់ មិនគេចវេសពីការទទួលទោស។ មើល ៣ ចំពោះបញ្ហាពាក់ព័ន្ធនឹងដីកាសន្និដ្ឋានជូន រឿងអោយស៊ើបសួររបស់ព្រះរាជអាជ្ញា។

៣. នៅពេលដែលកំពុងធ្វើអង្កេត ប្រមូលភ័ស្តុតាងបើយល់ថាការស៊ើបសួរបានបញ្ចប់ហើយពុំមាន ភស្តុតាងបន្ទុកជួយអោយចោទប្រកាន់ជនល្មើសបានទេ ចៅក្រមស៊ើបអង្កេតត្រូវធ្វើដីការលើកលែងចោទ

ប្រកាន់ ប៉ុន្តែមុននឹងធ្វើអ្នកសំរេចបែបនេះ ចៅក្រមស៊ើបសួរត្រូវធ្វើដីកាជូនរឿងទៅពិនិត្យទៅលោកព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានជាមុនសិន។ ព្រះរាជអាជ្ញាក្នុងរយៈ ៣ថ្ងៃ ជាធពីថ្ងៃទទួលសំណុំរឿងត្រូវធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរ ហើយបញ្ជូនសំណុំរឿងមកចៅក្រមស៊ើបអង្កេតវិញ ដើម្បីធ្វើតាសំរេច ។ ដីកាសំរេចនេះត្រូវបញ្ជាក់មូលហេតុអោយបានច្បាស់លាស់ ក្នុងរយៈ ពេល ២៤ ម៉ោង បើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍អំពីដីការសំរេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតមិនត្រូវដោះលែង ជនល្មើសអោយនៅក្រៅឃុំទេ បើជនល្មើសនេះត្រូវបានឃុំខ្លួន គឺជាជនល្មើសត្រូវនៅឃុំដដែល ហើយត្រូវចាត់ការ ប្រញាប់ប្រញាល់ជូនរឿងមកសាលាឧទ្ធរណ៍ តាមកំណត់ច្បាប់។ តែបើព្រះរាជអាជ្ញាបានយល់ព្រមតាមតាមលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតត្រូវធ្វើការដោះលែបជននោះភ្លាមៗ មិនត្រូវឃុំឃាំងទៅទៀតឡើយ។

៤. គោលការណ៍ត្រូវចងចាំៈ

- ចៅក្រមមិនអាចពន្លាតការស៊ើបអង្កេតរបស់ខ្លួនដោយខ្លួនឯងទៅលើហេតុការណ៍ថ្មីបានទេ។ ដូចនេះទាមទារឱ្យមានដីកាសន្និដ្ឋានបន្ថែមរបស់ព្រះរាជអាជ្ញាទើបអាចចាត់ការបាន។

- ដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាពុំមែនជាចំណងចងអោយចៅក្រម ធ្វើសេចក្តីសំរេចតាមឡើយ

- ចៅក្រមអាចពន្លាពការស៊ើបអង្កេតរបស់ខ្លួនទៅលើគ្រប់មនុស្ស ទោះបីឈ្មោះមនុស្សនោះមិនបានទៅទុក ក្នុងសេចក្តីសន្និដ្ឋានផ្តើមចោទរបស់ព្រះរាជអាជ្ញាក៏ដោយ អោយតែក្នុងសេចក្តីសន្និដ្ឋាននោះមានប្រើពាក្យ គូកន ឬ សហតត។

## III. តុលាការ

តុលាការមានអំណាចជំនុំជំរះក្នុងរឿងព្រហ្មទណ្ឌបានតែទៅលើជនជាប់ចោទទាំងឡាយណា ដែលព្រះរាជអាជ្ញាបានចោទប្រកាន់ និងបញ្ជូនរឿងទៅអោយជំនុំជំរៈ ឬតាមដីកាបញ្ជូនរឿងរបស់ចៅក្រមស៊ើបអង្កេត ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់រួចហើយ ឬតាមសាលក្រមបញ្ជូនរឿងរបស់តុលាការណាផ្សេងទៀត ឬតាមការនាំខ្លួនជនជាប់ ចោទជាបន្ទាន់ទៅទីសវនាកា ក្នុងករណីបទល្មើសជាក់ស្តែង។

ចៅក្រមណាដែលបានទទួលអង្កេតស៊ើបសួររឿងព្រហ្មទណ្ឌណាមួយហើយ ឬបានទទួលជំនុំជំរះរឿងនោះ ម្តងរួចហើយ ចៅក្រមនោះពុំអាចជំនុំជំរះរឿងដដែលនោះបានទៀតទេ។

ក្នុងករណីដែលតុលាការយល់ឃើញថា ការកំណត់បទល្មើសទៅលើអំពើដែលមាននៅក្នុងដីកាបញ្ជូនមកខ្លួនពុំត្រឹមត្រូវទេនោះ តុលាការអាចកែតម្រូវបទល្មើសអោយត្រូវទៅនឹងអំពើល្មើសនោះបាន ប៉ុន្តែមិនត្រូវបន្ថែមអ្វីទៅលើជាតុផ្សំ ដែលទាក់ទងជិតស្និទ្ធិទៅនឹងអំពើដែលបានលើកឡើងនៅក្នុងដីការចោទប្រកាន់ ឬដីកាបញ្ជូនរឿងនោះឡើយ ។

- ការកែតម្រូវនូវបទល្មើសនេះ ត្រូវបញ្ជាក់ច្បាស់ក្នុងមូលហេតុនៃសាលក្រម។

ក្នុងលក្ខណៈគ្មានភស្តុតាងគ្រប់គ្រាន់ដែលតុលាការយល់ថាមិនអាចជំនុំជំរះបាន ត្រូវចេញសាលក្រមរបៀបស៊ើអង្កេតដោយខ្លួនឯង ឬមួយប្រគល់ការងារស៊ើបអង្កេតនេះទៅឱ្យចៅព្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាធ្វើអង្កេតឡើងវីញក៏បាន។

តុលាការគ្មានអំណាចទុករឿងមិនជំនុំជំរះបានទេ លើកលែងតែក្នុងករណីមានការបន្ទាន់បង្ខំ ដែលត្រូវរង់ចាំតុលាការរដ្ឋប្បវេណីសំរេច អំពីករណីបន្ទាន់បង្ខំនោះជាមុនសិន។

អំពីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ដែលព្រះរាជអាជ្ញាបានចោទប្រកាន់បញ្ជូនសំណុំរឿងនិងខ្លួនជនល្មើសមកឱ្យតុលាការជំនុំជំរះ ចៅក្រមដែលទទួលកិច្ចការនេះ ត្រូវពិចារណាសំរេចអំពីការឃុំខ្លួន ឬការអោយទៅក្រៅឃុំដោយមានដាក់ប្រាក់ធានា ឬគ្មានប្រាក់ធានាជាបឋមសិនរួចហើយសឹមដាក់រឿងនេះជំនុំជំរះនៅពេលខាងមុខ ។

សាលក្រមសំរេចរបស់តុលាការ ដែលបានសំរេចផ្តន្ទាទោសជនល្មើស ត្រូវចង្អុលបទល្មើសដែលជននោះបានប្រព្រឹត្ត និងមាត្រាច្បាប់ ដែលតម្រូវអោយផ្តន្ទាទោស។ ម្យ៉ាងទៀតបើសាលក្រមសំរេចនោះមាននិយាយដល់បទសំណង និងជម្ងឺចិត្ត បញ្ហានេះក៏ត្រូវចង្អុលមាត្រាច្បាប់ និងកំណត់ចំនួនថ្ងៃដែលត្រូវដាក់ទុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់នោះ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំខាងលើនេះ ពិតមែនតែមិនទាន់បានសព្វគ្រប់ ប៉ុន្តែអាចជួយដល់ការងាររបស់អស់លោកជាចៅក្រម និងព្រះរាជអាជ្ញាទៅគ្រប់តុលាការខេត្ត-ក្រុង ក្នុងការអនុវត្តន៍នូវនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីជួបការលំបាក់ សូមអស់លោកលើកជាមតិស្នើឡើងមកក្រសួងយុត្តិធម៌ ក្រសួងនឹងធ្វើការណែនាំបន្ថែម ។

ហត្ថលេខា និងត្រា

**ចែម ស្ងួន**